ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Dec-2011, 09:50
CMS/CFO: Phok Chanthan

# ឧបសម្ព័ន្ធ ២៖ បញ្ជីសំអាងផ្លូវច្បាប់ស្តីពីការអនុវត្តរបស់រដ្ឋទាក់ទិននឹងការវិវឌ្ឍនៃជម្លោះប្រដាប់អាវុធជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ (ឆ្នាំ១៨៦៨-បច្ចុប្បន្ន)

គោលបំណងនៃឧបសម្ព័ន្ធនេះគឺដើម្បីបង្ហាញអំពីដើមកំណើតនៃលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជម្លោះប្រដាប់អាវុធនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាមរយៈការពិនិត្យទៅលើលិខិតូបករណ៍អន្តរជាតិ និងច្បាប់ជាតិនានា។

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | **ឆ្នាំ៖ មុនឆ្នាំ១៩៤៥** | | | |
| 1. | សេចក្តីប្រកាសអំពីការបញ្ឈប់ការប្រើប្រាស់គ្រាប់ផ្លោងដែលមានទម្ងន់ក្រោម ៤00ក្រាម ក្នុងអំឡុងពេលសង្គ្រាម , Saint Petersburg, ចូលជាធរមាន ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៨៦៨ | 1868 | មាន (ពីព្រោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិកំពុងតែវិវឌ្ឍ) | "ផ្អែកលើសំណើរបស់គណៈរដ្ឋមន្ត្រីរុស្ស៊ី គណៈកម្មការយោធាអន្តរជាតិបានជួបប្រជុំគ្នានៅ St. Petersburg ដើម្បីពិនិត្យអំពីភាពស័ក្តិសមនៃការហាមឃាត់ការប្រើប្រាស់គ្រាប់ផ្លោងមួយចំនួនក្នុងអំឡុងពេលសង្គ្រាមរវាងបណ្តាប្រទេសដែលមានអារ្យធម៌ខ្ពង់ខ្ពស់។ គណៈកម្មការនោះ ដោយមានការព្រមព្រៀងរួមគ្នាបានកំណត់ការកម្រិតផ្នែកបច្ចេកទេស ដែលភាពចាំបាច់នៃសង្គ្រាមគួរតែស្របទៅនឹងលក្ខខណ្ឌតម្រូវនៃមនុស្សជាតិ អ្នកចុះហត្ថលេខាបានទទួលការបង្គាប់បញ្ជាពីរដ្ឋាភិបាលរបស់ពួកគេដើម្បីប្រកាស..." |



Original EN: 00755484-00755505

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | (បុព្វកថា)<br><br>"ដូច្នេះ ការប្រើប្រាស់អាវុធបែបនេះ នឹងផ្ទុយទៅនឹងច្បាប់មនុស្សជាតិ" (សេចក្តីប្រកាស)<br><br>**សេចក្តីអត្ថាធិប្បាយ** ៖<br>ការដាក់បញ្ចូលរបស់ធម្មនុញ្ញ Nuremberg នូវទំនាក់ទំនងជម្លោះប្រដាប់អាវុធនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឆ្លុះបញ្ចាំងនូវការវិវឌ្ឍនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលកើតចេញមកពីច្បាប់ និងទំនៀមទម្លាប់សង្គ្រាមនៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០។ អ្នកធ្វើសេចក្តីព្រាងធម្មនុញ្ញ Nuremberg បានដាក់បញ្ចូលទំនាក់ទំនង ដើម្បីកុំឱ្យមានការចោទប្រកាន់ថា គោលការណ៍នីត្យានុកូលភាពត្រូវបានរំលោភបំពាន។ (បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ("បណ្តឹងសាទុក្ខរបស់ អៀង |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | សារី ប្រឆាំងនឹងសេចក្តីសម្រេចអំពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ") កថាខណ្ឌ ២៧) |
| 2. | អនុសញ្ញាទីក្រុងឡាអេ (II) ស្តីពីច្បាប់ និងទំនៀមទម្លាប់សង្គ្រាមផ្លូវគោក និង ឧបសម្ព័ន្ធរបស់ច្បាប់នេះ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ | 1899 | មាន (ពីព្រោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិកំពុងតែវិវឌ្ឍ) | "ត្រូវបានលើកទឹកចិត្តដោយចេតនាដើម្បីបម្រើផលប្រយោជន៍មនុស្សជាតិ និងលក្ខខណ្ឌតម្រូវដែលចេះតែកើនឡើងនៃអារ្យធម៌ សូម្បីនៅក្នុងសម្មតិកម្មដាច់ខាតក៏ដោយ... " (បុព្វកថា)។<br><br>"រហូតដល់មានការចេញក្រមនៃច្បាប់សង្គ្រាមដែលមានលក្ខណៈពេញលេញមួយ ភាគីផ្តល់សច្ចាប័នយល់ឃើញថាវាចាំបាច់ណាស់ដើម្បីប្រកាសថា ក្នុងករណីដែលមិនមានបញ្ចូលនៅក្នុងបញ្ញត្តិដែលភាគីទាំងនេះបានអនុម័ត អ្នកស្រុក និងពួកបច្ចាមិត្ត នៅតែស្ថិតនៅក្រោមការការពារ និងវិធាននៃគោលការណ៍ច្បាប់របស់ប្រទេសដោយសារតែវាកើតចេញមកពីការប្រើប្រាស់នានាដែលបង្កើតឡើងក្នុងចំណោមប្រជាជនដែលមានអារ្យធម៌ខ្ពង់ខ្ពស់ កើតចេញមកពីច្បាប់មនុស្សជាតិ និងលក្ខណៈតម្រូវចាំបាច់នៃមនសិការសាធារណៈ ..." (បុព្វកថា)។ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| 3. | អនុសញ្ញាទីក្រុងឡាអេ (IV) ស្ដីពី ច្បាប់ និងទំនៀមទម្លាប់សង្គ្រាមផ្លូវគោក និង ឧបសម្ព័ន្ធរបស់ច្បាប់នេះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ | 1907 | មាន<br>(ពីព្រោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិកំពុងតែវិវឌ្ឍ) | "ត្រូវបានលើកទឹកចិត្តដោយចេតនាដើម្បីបម្រើផលប្រយោជន៍មនុស្សជាតិ សូម្បីនៅក្នុងករណីដាច់ខាតក៏ដោយ... " (បុព្វកថា)។<br><br>"រហូតដល់មានការចេញក្រមនៃច្បាប់សង្គ្រាមដែលមានលក្ខណៈពេញលេញមួយ ភាគីផ្ដល់សច្ចាប័នយល់ឃើញថាវាចាំបាច់ណាស់ដើម្បីប្រកាសថា ក្នុងករណីនានាដែលមិនមានបញ្ចូលនៅក្នុងបញ្ញត្តិដែលភាគីទាំងនេះបានអនុម័ត អ្នកស្រុក និងពួកបច្ចាមិត្ត នៅតែស្ថិតនៅក្រោមការការពារ និងវិធាននៃគោលការណ៍ច្បាប់របស់ប្រទេសដោយសារតែវាកើតចេញមកពីការប្រើប្រាស់នានាដែលបង្កើតឡើងក្នុងចំណោមប្រជាជនដែលមានអារ្យធម៌ខ្ពង់ខ្ពស់ កើតចេញមកពីច្បាប់មនុស្សជាតិ និងគោលការណ៍តម្រូវនៃមនសិការសាធារណៈ ..." (បុព្វកថា)។<br><br>**សេចក្ដីអត្ថាធិប្បាយ ៖**<br>"ពាក្យ 'ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព' 'ឧក្រិដ្ឋកម្មសង្គ្រាម' និង 'ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ' ទោះបីជាប្រើនៅក្នុង [ធម្មនុញ្ញ |

| លេខ | ឈ្មោះប្រភេទឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | តុលាការ IMT និងធម្មនុញ្ញ Tokyo និងច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង] ជាពាក្យបច្ចេកទេសក៏ដោយ មិនតំណាងឲ្យទស្សនទានថ្មីទាំងស្រុង ឬដោយពុំមានយុត្តិសាស្ត្រឡើយ... ទាក់ទិនជាមួយនឹងការវិវឌ្ឍនៃច្បាប់សង្គ្រាមមុនសង្គ្រាមលោកលើកទី I គ្រប់ការយោងទាំងអស់ទៅលើ 'មនុស្សជាតិ' ដូចជា 'ផលប្រយោជន៍មនុស្សជាតិ' 'គោលការណ៍មនុស្សជាតិ' និង 'ច្បាប់មនុស្សជាតិ' ដូចដែលបានចែងនៅក្នុងអនុសញ្ញាទីក្រុងឡាអេទីបួន ឆ្នាំ១៩០៧ និងនៅក្នុងឯកសារ និងបញ្ញត្តិច្បាប់ផ្សេងៗទៀតនៅក្នុងអំឡុងពេលនោះ ត្រូវបានប្រើនៅក្នុងន័យមិនមែនបច្ចេកទេស ហើយពិតណាស់មិនមានគោលបំណងចង្អុលបង្ហាញនូវបទដ្ឋានមួយចំនួន ដែលខុសពី 'ច្បាប់ និងទំនៀមទម្លាប់សង្គ្រាម' ដែលត្រូវបានក្តោបដោយពាក្យ 'ឧក្រិដ្ឋកម្មសង្គ្រាម' នៅក្នុងឯកសារឆ្នាំ ១៩៤៥ និងឆ្នាំ ១៩៤៦ ឡើយ"។ (គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ និងការវិវឌ្ឍនៃច្បាប់សង្គ្រាម ("ប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការ សហប្រជាជាតិ") (ឆ្នាំ១៩៤៨) ទំព័រ ១៨៨-៨៩)។ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | |
| 4. | សេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំង ចក្រភពអង់គ្លេស និងរុស្ស៊ី ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩១៥ | 1915 | មាន (ពីព្រោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិកំពុងតែវិវឌ្ឍ) | "ដោយពិចារណាទៅលើឧក្រិដ្ឋកម្មថ្មីៗទាំងនេះរបស់ប្រទេសទួរគីប្រឆាំងនឹងមនុស្សជាតិ និងអារ្យធម៌ រដ្ឋាភិបាលសម្ព័ន្ធមិត្តប្រកាសជាសាធារណៈដល់អាណាចក្រ Ottoman ថា ពួកគេនឹងទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មទាំងនេះ គ្រប់សមាជិកទាំងអស់របស់រដ្ឋាភិបាល Ottoman និងគ្រប់ភ្នាក់ងារទាំងអស់ដែលជាប់ពាក់ព័ន្ធនៅក្នុងការសម្លាប់រង្គាលនេះ" ទំព័រ១។<br><br>**សេចក្តីអត្ថាធិប្បាយ ៖**<br>ជាមួយនឹងសេចក្តីប្រកាសនេះ "សង្គ្រាមលោកលើកទី I បានមើលឃើញសហគមន៍អន្តរជាតិចាត់វិធានការដំបូងឆ្ពោះទៅការបង្កើតឧក្រិដ្ឋកម្មជាក់លាក់មួយ ដែលមានឈ្មោះថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"" (អៀង សារី ឧបសម្ព័ន្ធ៖ សេចក្តីសង្ខេបនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការវិវឌ្ឍន៍នៃឧក្រិដ្ឋកម្មទាំងនេះនៅក្នុងយុត្តិសាស្ត្រអន្តរជាតិ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D378/2.2 កថាខណ្ឌ ៣)។ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| 5. | កិច្ចព្រមព្រៀង Nyon ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៣៧ | 1937 | មាន (ពីព្រោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិកំពុងតែវិវឌ្ឍ) | "រីឯការវាយប្រហារទាំងនេះ គឺជាការរំលោភលើវិធាននៃច្បាប់អន្តរជាតិ ដែលត្រូវបានយោង នៅក្នុងផ្នែក IV នៃសន្ធិសញ្ញា London ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៣០ ទាក់ទិននឹង ការលិចនាវាពាណិជ្ជកម្ម និងបង្កើតបានជាអំពើផ្ទុយទៅនឹងគោលការណ៍តម្រូវសំខាន់បំផុតនៃមនុស្សជាតិ ដែលគួរតែត្រូវបានចាត់ទុកយ៉ាងត្រឹមត្រូវថាជាអំពើនៃការប្លន់តាមសមុទ្រ ..." (បុព្វកថា)។ |
| 6. | ក្រឹត្យប្រទេសបែលហ្ស៊ិក (Arrêté) ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៤៤ (ដូចដែលបានដកស្រង់ដោយប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ) | 1944 | មិនច្បាស់ | "...ការរំលោភជាច្រើនទៅលើវិធាននៃច្បាប់អន្តរជាតិ និងទៅលើកាតព្វកិច្ចរបស់មនុស្សជាតិ (des devoirs d'humanite) ត្រូវបានប្រព្រឹត្តឡើងដោយអ្នកឈ្លានពាន" (ទំព័រ ២១៧-១៨)។<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>"ទាំងនៅក្នុងលក្ខន្តិកៈ Luxembourg និងលក្ខន្តិកៈ Belgian ពាក្យ<br>'កាតព្វកិច្ចរបស់មនុស្សជាតិ'...គឺកម្រប្រើនៅក្នុងន័យបច្ចេកទេសណាស់ ដែល 'ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ' ត្រូវបានអនុម័ត |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | នៅក្នុងធម្មនុញ្ញ London (ក្រោយមកទៀត) ដែលចុងក្រោយ Belgium និង Luxembourg បានយកតាម"។ (ទំព័រ ២១៨) |
| | **ឆ្នាំ១៩៤៥-១៩៥៤** | | | |
| 7. | ក្រឹត្យច្បាប់រូម៉ានី ខែ មេសា ឆ្នាំ ១៩៤៥ *(ដូចដែលបានដកស្រង់ដោយប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ)* | 1945 | មិនច្បាស់ | ច្បាប់នេះដាក់ទណ្ឌកម្មដល់អ្នករំលោភលើវិធានសង្គ្រាម និងជនទាំងឡាយ "ដែលបានបញ្ជា ឬបានប្រព្រឹត្តអំពើគាបសង្កត់ មិនថាជារួម ឬជាលក្ខណៈបុគ្គលឡើយ ស្របតាមផែនការជាតិសាសន៍ ឬ ឬនយោបាយ" ឬ "ការផ្លាស់ទីកន្លែង និងការដឹកជញ្ជូនមនុស្សក្នុងគោលបំណងដើម្បីសម្លាប់ពួកគេបំផុតពូជ" ឬ "បានប្រព្រឹត្តអមនុស្សធម៌ទៅលើជនទាំងឡាយដែលស្ថិតនៅក្នុងអំណាចរបស់ពួកគេ"។ (ទំព័រ ២១៨)<br><br>**សេចក្តីអត្ថាធិប្បាយ ៖**<br><br>"…ច្បាប់នេះទំនងជាមាននៅក្នុងធម្មនុញ្ញ [តុលាការ IMT]"។ (ទំព័រ ២១៨) |

| លេខ | ឈ្មោះប្រភេទឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| 8. | ក្រឹត្យ Grand Ducal, Luxembourg ថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ១៩៤៥ (*ដូចដែលបានដកស្រង់ដោយប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ*) | 1945 | មិនច្បាស់ | "…ចំពោះការរំលោភបំពានមួយចំនួនទៅលើច្បាប់អន្តរជាតិ និងទៅលើកាតព្វកិច្ចរបស់មនុស្សជាតិ (des devoirs de l'humanite) ដែលត្រូវបានប្រព្រឹត្តដោយអ្នកឈ្លានពាន…" (បុព្វកថា) (ទំព័រ ២១៨)។<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>"ទាំងនៅក្នុងលក្ខន្តិកៈ Luxembourg និងលក្ខន្តិកៈ Belgian ពាក្យ 'កាតព្វកិច្ចរបស់មនុស្សជាតិ'…គឺកម្រប្រើនៅក្នុងន័យបច្ចេកទេសណាស់ ដែល 'ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ' ត្រូវបានអនុម័តនៅក្នុងធម្មនុញ្ញ London (ក្រោយមកទៀត) ដែលចុងក្រោយ Belgium និង Luxembourg បានយកតាម"។ (ទំព័រ ២១៨) |
| 9. | ច្បាប់រដ្ឋធម្មនុញ្ញអូស្ត្រាលី ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៤៥ (*ដូចដែលបានដកស្រង់ដោយប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ*) | 1945 | មាន | 'នៅក្នុងអំឡុងពេលនៃសង្គ្រាមនេះ ដោយប្រព្រឹត្តដើម្បីផលប្រយោជន៍ពិតប្រាកដ ឬសន្មតថាជាផលប្រយោជន៍របស់កងកម្លាំងប្រដាប់អាវុធអាល្លឺម៉ង់ ឬរបស់អំណាចផ្តាច់ការជាតិសង្គមនិយម ជនណាដែលបានប្រព្រឹត្ត ឬបានញុះញង់ឲ្យមានអំពើដែលផ្ទុយទៅ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | នឹងគោលការណ៍ធម្មជាតិរបស់មនុស្សជាតិប្រឆាំងនឹងបុគ្គលណាមួយ ទោះបីជាពាក់ព័ន្ធនឹងសកម្មភាពយោធា ឬចម្បាំង ឬសកម្មភាពរបស់ក្រុមដែលត្រូវបានរៀបចំឡើងតាមបែបយោធាក៏ដោយ ត្រូវបានចាត់ទុកថាមានពិរុទ្ធភាពចំពោះបទល្មើសដូចគ្នា"។ (ទំព័រ ២១៨) |
| 10. | ធម្មនុញ្ញតុលាការយោធាអន្តរជាតិ ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ | 1945 | មាន | មាត្រា ៦(គ)៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ "ពោលគឺការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ ពីមុនឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅក្នុងការអនុវត្ត ឬការជាប់ទាក់ទងជាមួយនឹងឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ ទោះបីជាអំពើទាំងនេះរំលោភបំពាន ឬមិនរំលោភបំពានច្បាប់ជាតិ នៃប្រទេសដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក្តីក៏ដោយ"។ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | **សេចក្តីអត្ថាធិប្បាយៈ**<br>វាមិនមែនមានលក្ខណៈមិនច្បាស់នោះទេចំពោះថាតើលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងដែលមានមានចែងនៅក្នុងធម្មនុញ្ញ Nuremberg គឺជាដែនកំណត់ផ្នែកយុត្តាធិការដែលជាលក្ខណៈពិសេសតែមួយគត់នៅក្នុងធម្មនុញ្ញ ឬយ៉ាងណានោះ។ ចៅក្រមតុលាការ IMT បញ្ជាក់យ៉ាងច្បាស់ថា ធម្មនុញ្ញនេះតំណាងឱ្យច្បាប់អន្តរជាតិដែលមានជាធរមាន នៅពេលដែលធម្មនុញ្ញនេះត្រូវបានបង្កើតឡើង។ (បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ កថាខណ្ឌ ២៧-២៨)។ |
| 11. | ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ | 1945 | មិនច្បាស់ | មាត្រា ១៖ "សេចក្តីប្រកាសទីក្រុងម៉ូស្គូ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៤៣ 'ស្តីពីការទទួលខុសត្រូវរបស់ Hitlerites ចំពោះអំពើឃោរឃៅដែលត្រូវបានប្រព្រឹត្ត' និងកិច្ចព្រមព្រៀង London ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ [ធម្មនុញ្ញតុលាការ IMT] 'ស្តីពីការចោទប្រកាន់ និងការដាក់ទោសទណ្ឌចំពោះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗរបស់ប្រទេសសម្ព័ន្ធមិត្តអឺរ៉ុប' គឺជាផ្នែកដ៏សំខាន់នៃច្បាប់ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | នេះ”។<br><br>មាត្រា II(គ)៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ អំពើឃោរឃៅ និងជាឧក្រិដ្ឋកម្ម ដែលរួមមានអំពើជាច្រើនដូចជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ឬអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ទោះបីជាអំពើទាំងនេះរំលោភបំពាន ឬមិនរំលោភបំពានច្បាប់ជាតិនៃប្រទេសដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក៏ដោយ”។ |
| 12. | ក្រឹត្យដាក់ទោសទណ្ឌរបស់ Czechoslovakia ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៤៥ (*ដូចដែលបានដកស្រង់ដោយប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការ* | 1945 | មិនច្បាស់ | ក្រឹត្យនេះ “មាន... បទប្បញ្ញត្តិ ទាក់ទិននឹងសមាជិកភាពនៅក្នុងអង្គការឧក្រិដ្ឋ (ផ្នែក ២ និងផ្នែក ៣(២) និរទេសដើម្បីឲ្យធ្វើពលកម្មដោយបង្ខំ (ផ្នែក ៦) ការដាក់ក្នុងមន្ទីរឃុំឃាំងដែលគ្មានយុត្តិកម្ម (ផ្នែក ៧) និងផងដែរសំដៅលើ ‘ការធ្វើទុក្ខបុកម្នេញដោយ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | *សហប្រជាជាតិ)* | | | មូលហេតុជាតិសាសន៍ នយោបាយ ឬពូជសាសន៍' (ផ្នែក ១០"។ (ទំព័រ ២១៧)។<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>"នៅក្នុងធម្មនុញ្ញ London អ្វីដែលគេហៅថាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិ ត្រូវបានចាត់ទុកថាជាការរំលោភបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌក្រុងមុនឆ្នាំ១៩៣៨ នៅក្នុងក្រឹត្យដាក់ទោសទណ្ឌរបស់ Czechoslovakia." (ទំព័រ ២១៧)។ |
| 13. | បញ្ញត្តិរបស់គណៈកម្មការយោធានៅក្នុងតំបន់សង្គ្រាមប្រទេសចិន និងចុងបូព៌ា ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ១៩៤៥ *(ដូចដែលបានដកស្រង់ដោយប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ)* | 1945 | មាន | ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានកំណត់និយមន័យថាជា៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ ពីមុនឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅក្នុងការអនុវត្ត ឬការជាប់ទាក់ទងជាមួយនឹង |

| លេខ | ឈ្មោះប្រភេទឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ ទោះបីជាអំពើទាំងនេះរំលោភបំពាន ឬមិនរំលោភបំពានច្បាប់ជាតិ នៃប្រទេសដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក្តីក៏ដោយ” (ទំព័រ ២១៥) |
| 14. | ធម្មនុញ្ញតុលាការយោធាអន្តរជាតិចុងបូព៌ា (“IMTFE”) ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦ | 1946 | មាន | មាត្រា ៥(គ)៖ “ពោលគឺ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ ពីមុនឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅក្នុងការអនុវត្ត ឬការជាប់ទាក់ទងជាមួយនឹងឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ ទោះបីជាអំពើទាំងនេះរំលោភបំពាន ឬមិនរំលោភបំពានច្បាប់ជាតិ នៃប្រទេសដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក្តីក៏ដោយ” |
| 15. | បត្យាប័ន និងការដាក់ទោសទណ្ឌឧក្រិដ្ឋជនសង្គ្រាម U.N.G.A. Res. 3(I), ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៤៦ | 1946 | មាន | “...កត់សម្គាល់អំពីច្បាប់ និងការប្រើប្រាស់សង្គ្រាម ដែលបង្កើតឡើងដោយអនុសញ្ញាទីក្រុងឡាអេទីបួន ឆ្នាំ១៩០៧។ កត់សម្គាល់និយមន័យនៃឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ជាតិនៅក្នុង [ធម្មនុញ្ញតុលាការ IMT] ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥។ ជឿជាក់ថា ឧក្រិដ្ឋជនសង្គ្រាមមួយចំនួន បន្តគេចវេះពីយុត្តិធម៌នៅក្នុងទឹកដីរបស់រដ្ឋមួយចំនួន។ *ផ្តល់យោបល់*ថា សមាជិករបស់ [អង្គការសហប្រជាជាតិ] ... បណ្តាលឲ្យមានការចាប់ខ្លួនឧក្រិដ្ឋជនសង្គ្រាមទាំងនោះ... និងបណ្តាលឲ្យមានការបញ្ជូនខ្លួនពួកគេទៅកាន់ប្រទេសដែលពួកគេបានប្រព្រឹត្តអំពើឧក្រិដ្ឋទាំងនោះ” (ទំព័រ ១០)។ |
| 16. | ច្បាប់ដាណឺមាក ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៤៦ (*ដូចដែលបានដកស្រង់ដោយប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ*) | 1946 | មាន | “ក្រៅពីឧទាហរណ៍ដែលបានដកស្រង់នៅក្នុងកថាខណ្ឌ I ជនដែលបានប្រព្រឹត្តបទល្មើសខាងក្រោមនេះ ត្រូវតែទទួលរងនូវការចោទប្រកាន់ក្រោមច្បាប់នេះ៖ ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចជា ការធ្វើមនុស្សឃាត ការធ្វើបាបជនស៊ីវិល អ្នកទោស ទាហានកងនាវា ការសម្លាប់ចំណាប់ខ្មាំង ការលួចប្លន់ទ្រព្យសម្បត្តិសាធារណៈ ឬទ្រព្យសម្បត្តិឯកជន ការទាមទារយកលុយកាក់ ឬវត្ថុមានតម្លៃផ្សេងៗទៀត ការរំលោភលើរដ្ឋធម្មនុញ្ញ ការដាក់ទណ្ឌកម្មជារួម បំផ្លិចបំផ្លាញដោយប្រើគ្រឿងផ្ទុះ ឬវិធីផ្សេង |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ទៀត ក្នុងវិសាលភាពដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើងដោយរំលោភទៅលើវិធាន និងច្បាប់អន្តរជាតិដែលចែងទាក់ទិននឹងការត្រួតត្រា និងសង្គ្រាម។ ច្បាប់នេះ ត្រូវយកមកអនុវត្តបន្ថែមទៀត ... ចំពោះគ្រប់សកម្មភាពទាំងអស់ ដែលត្រូវបានក្តោបដោយមាត្រា ៦ នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ ទោះបីជាសកម្មភាពទាំងអស់នោះមិនត្រូវបានដកស្រង់ឲ្យបានជាក់លាក់នៅខាងលើក៏ដោយ”។ (ទំព័រ ២១៩)។<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>មាត្រា ៦ នៃធម្មនុញ្ញ London “ត្រូវបានដាក់បញ្ចូលយ៉ាងច្បាស់នៅក្នុងច្បាប់ជាតិដាណឺមាក”។ (ទំព័រ ២១៩) |
| 17. | ការតម្កល់គោលការណ៍ច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ដោយធម្មនុញ្ញរបស់តុលាការ Nürnberg U.N.G.A. Res. 95(I) ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦ | 1946 | មាន | “*មហាសន្និបាត ... តម្កល់* គោលការណ៍ច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ដោយធម្មនុញ្ញតុលាការ Nürnberg និងសាលក្រមរបស់តុលាការ។ *ដឹកនាំ*គណៈកម្មាធិការស្តីពីការចងក្រងច្បាប់អន្តរជាតិ ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | មហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦ ឱ្យចាត់ទុកថាជាបញ្ហាមួយនៃផែនការដែលមានសារៈសំខាន់បំផុត សម្រាប់ការតាក់តែង នៅក្នុងបរិបទនៃការចងក្រងជាក្រមច្បាប់ទូទៅនៃបទល្មើសនានាប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ ឬនៃក្រមព្រហ្មទណ្ឌអន្តរជាតិ នៃគោលការណ៍ដែលត្រូវបានទទួលស្គាល់នៅក្នុងធម្មនុញ្ញតុលាការ Nürnberg និងនៅក្នុងសាលក្រមរបស់តុលាការ។ |
| 18. | អនុសញ្ញាប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ ស្តីពីការទប់ស្កាត់ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៤៨, 78 UNTS 277 | 1948 | មិនមាន | មាត្រា ១៖ “ភាគីផ្តល់សច្ចាប័នអះអាងថា អំពើប្រល័យពូជសាសន៍ ទោះបីជាប្រព្រឹត្តឡើងក្នុងពេលមានសន្តិភាព ឬក្នុងពេលសង្គ្រាមក៏ដោយ គឺជាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ដែលរដ្ឋទាំងនោះអនុវត្តដើម្បីទប់ស្កាត់ និងផ្តន្ទាទោស”។<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>អនុសញ្ញាប្រល័យពូជសាសន៍ ពុំបានបង្ហាញអំពីការអនុវត្តរបស់រដ្ឋទាក់ទិននឹងទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធឡើយ។ ឧក្រិដ្ឋកម្ម |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាបទល្មើសដោយឡែកពីគ្នាតាមផ្លូវច្បាប់៖ ក. ឧក្រិដ្ឋកម្មនីមួយៗមាន*ធាតុផ្សំអត្តនោម័ត*ដោយឡែកពីគ្នា និង **ខ.** មិនដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ពុំបានតម្រូវថា អំពើត្រូវកើតឡើងជាផ្នែកនៃការវាយប្រហារដែលមានលក្ខណៈរាលដាល ឬជាប្រព័ន្ធឡើយ។ លើសពីនេះទៀត ការដកលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជាសាសន៍ មិនមានផលប៉ះពាល់ដល់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។ (បណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ កថាខណ្ឌ ៤២-៤៣)។ |
| 19. | ច្បាប់ (ផ្ដន្ទាទោស) អ្នកចូលដៃជាមួយពួកណាស៊ី និងពួកណាស៊ី ឆ្នាំ ១៩៥០ (អ៊ីស្រាអែល) | 1950 | មិនមាន | មាត្រា ១៖ "'ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ' គឺសំដៅទៅលើអំពើដូចខាងក្រោមនេះ ៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការបង្អត់អាហារ ឬការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជន |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ស៊ីវិលណាមួយ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា"។ |
| 20. | កំណត់ហេតុសង្ខេប នៃកិច្ចប្រជុំលើកទី ៤៨ របស់គណៈកម្មការច្បាប់អន្តរជាតិ (ប្រធានបទ៖ ការបង្កើតគោលការណ៍ Nürnberg), A/CN.4/SR.48 ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៥០ | 1950 | មាន | "ប្រធានបានមានប្រសាសន៍ថា មាត្រា ៦(គ) របស់តុលាការ Nürnberg រួមបញ្ចូលនូវបទល្មើសដែលត្រូវបានប្រព្រឹត្ត 'មុន ឬក្នុងអំឡុងពេលសង្គ្រាម'។ គាត់គិតថា តាមពិតអ្នកធ្វើសេចក្តីរាយការណ៍បានបកស្រាយកិច្ចការនេះនៅក្នុងន័យចង្អៀត ហើយថា គណៈកម្មការមានសិទ្ធិត្រួតពិនិត្យការបកស្រាយនេះ។ គាត់បានស្នើឱ្យលុបចោលពាក្យពេចន៍ 'នៅពេលដែលអំពើទាំងនោះ ត្រូវបានប្រព្រឹត្ត ឬការធ្វើទុក្ខបុកម្នេញនោះត្រូវបានធ្វើឡើងនៅក្នុងការអនុវត្ត ឬការជាប់ទាក់ទងជាមួយនឹងឧក្រិដ្ឋកម្មណាមួយប្រឆាំងនឹងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាមណាមួយ'"។ (កថាខណ្ឌ ៩០)<br><br>"លោក SPIROPOULOS បានជំទាស់ទៅនឹងការស្នើឡើងនេះ [លុបចោលទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ]។ សាលក្រម បានបកស្រាយធម្មនុញ្ញនេះ ហើយគណៈកម្មការត្រូវតែគោរពតាមសាលក្រម"។ (កថាខណ្ឌ ៩១) |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | "លោក AMADO…គាំទ្រអត្ថបទនេះ [ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ] ដូចដែលមាននៅក្នុងរបាយការណ៍"។ (កថាខណ្ឌ ៩៤)<br><br>លោក HUDSON បានជំទាស់ថា "ទំនាក់ទំនងទៅនឹងសង្គ្រាមត្រូវតែរក្សាទុក"។ (កថាខណ្ឌ ៩៥)<br><br>លោក ALFARO បានជំទាស់ថា "ចុងបញ្ចប់នៃកថាខណ្ឌ [ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ] មានលក្ខណៈចាំបាច់ណាស់ដើម្បីដាក់ឧក្រិដ្ឋកម្មទាំងនេះនៅក្រោមច្បាប់អន្តរជាតិ"។ (កថាខណ្ឌ ១០៣)<br><br>"លោក BRIERLY គិតថា ឧក្រិដ្ឋកម្ម … អាចត្រូវបានប្រព្រឹត្តសូម្បីតែនៅទីកន្លែងដែលពុំមានសង្គ្រាម។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាឧក្រិដ្ឋកម្មមួយ ទោះបីជាពុំមានសង្គ្រាមក៏ដោយ"។ (កថាខណ្ឌ ១១៧)<br><br>"ប្រធាន គិតថា ដល់ពេលដែលត្រូវធ្វើការសម្រេចហើយ ហើយ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | គាត់បានសួរគណៈកម្មការថាតើ គណៈកម្មការចង់រក្សាទុកអត្ថបទនៃកថាខណ្ឌ (គ) ដូចដែលមាននៅក្នុងរបាយការណ៍ ឬយ៉ាងណា"។ កថាខណ្ឌ ១២៦)<br><br>*"មានការសម្រេចថារក្សាទុកអត្ថបទនោះ"។* (ទំព័រ ៥៨) |
| 21. | គោលការណ៍នៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់នៅក្នុងធម្មនុញ្ញរបស់តុលាការ Nürnberg និងនៅក្នុងសេចក្តីសម្រេចរបស់តុលាការ A/1316, ឆ្នាំ១៩៥០ | 1950 | មាន | គោលការណ៍ VI (គ)៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន "ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ ឬការធ្វើទុក្ខបុកម្នេញដោយសារតែមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅពេលអំពើបែបនោះ ត្រូវបានប្រព្រឹត្ត ឬការធ្វើទុក្ខបុកម្នេញបែបនោះត្រូវបានប្រព្រឹត្តក្នុងការអនុវត្ត ឬជាប់ពាក់ព័ន្ធនឹងបទល្មើសប្រឆាំងនឹងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាមណាមួយ"។<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>អង្គជំនុំជម្រះសាលាដំបូង មិនបានពិចារណាគោលការណ៍ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | Nuremberg ថាជាសេចក្តីថ្លែងសំខាន់របស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលបានចងក្រងគោលការណ៍នៃទំនៀមទម្លាប់អន្តរជាតិនាពេលនោះ។ បន្ថែមពីលើនេះ មហាសន្និបាតអង្គការសហប្រជាជាតិ បានគាំទ្រគោលការណ៍ទាំងនេះ។ (បណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចដែលទាក់ទងនឹងជម្លោះប្រដាប់អាវុធ កថាខណ្ឌ ៣៧-៣៨)។ |
| 22. | កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី៩០ របស់គណៈកម្មាធិការច្បាប់អន្តរជាតិ (ILC) (ប្រធានបទ៖ សេចក្តីព្រាងក្រមអំពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ ផ្នែកទីI), A/CN.4/SR.90, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៥១ | 1951 | មិនច្បាស់ | "លោក SPIROPOULOS បានរំឭកថា ក្នុងកិច្ចប្រជុំលើកមុន គណៈកម្មាធិការបានពិចារណាថា អំពើនានាដែលមានចែងនៅក្នុងកថាខណ្ឌ៩ គឺជាបទល្មើសក្រោមច្បាប់អន្តរជាតិ លុះត្រាតែបទល្មើសទាំងនោះជាប់ទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព។ នៅក្នុងគណៈកម្មាធិការទីប្រាំមួយ គណៈប្រតិភូបារាំងបានរិះគន់ទស្សនៈនោះថាមានលក្ខណៈចង្អៀតខ្លាំងពេក។ គណៈប្រតិភូបារាំងបានពិចារណាថា វាគួរតែមានបទល្មើសប្រឆាំងនឹងមនុស្សជាតិនៅក្នុងពេលសន្តិភាព ដូចគ្នានឹងក្នុងមានសង្គ្រាមដែរ។ ប្រសិនបើគាត់ចងចាំមិនខុសទេនោះ គ្មាន |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | គណៈប្រតិភូដទៃទៀត គាំទ្រគំនិតនោះទេ” (កថាខណ្ឌ ១៣៨-៣៩)។ |
| 23. | របាយការណ៍ទីពីរស្ដីពីសេចក្ដីព្រាងក្រមអំពីបទល្មើសប្រឆាំងនឹងសន្តិភាពនិងសន្តិសុខរបស់មនុស្សជាតិ រៀបចំដោយលោក J. Spiropoulos ដែលជាអ្នករាយការណ៍ពិសេស (ប្រធានបទ៖ សេចក្ដីព្រាងក្រមអំពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ ផ្នែកទីI), A/CN.4/44, 1951 | 1951 | មាន | ទស្សនៈដែលទាក់ទងនឹងគោលការណ៍Nürnberg គោលការណ៍VI(គ) (ចាប់ផ្ដើមត្រង់កថាខណ្ឌ ១១៦)៖<br><br>AMADO: “ទោះបីជាយ៉ាងណាក៏ដោយ មានបំណងទាញការចាប់អារម្មណ៍របស់គណៈកម្មាធិការឲ្យពិនិត្យត្រង់កថាខណ្ឌ១២០របស់របាយការណ៍ ដែលទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ អំពើទាំងនោះគឺជាបទល្មើសអន្តរជាតិតែប៉ុណ្ណោះ នៅពេលដែលប្រព្រឹត្ត ទាក់ទងនឹងបទល្មើសផ្សេងទៀតដែលស្ថិតនៅក្នុងប្រភេទនៃបទល្មើសប្រឆាំងនឹងសន្តិភាពនិងឧក្រិដ្ឋកម្មសង្គ្រាម”(កថាខណ្ឌ ១១៦)។<br>“CHAUMONT… នៅក្នុងគោលការណ៍VI គណៈកម្មាធិការរក្សាគំនិតដែលមាននៅក្នុងធម្មនុញ្ញNürnberg បទល្មើសប្រឆាំងនឹងមនុស្សជាតិ មានចំណងទាក់ទងនឹងបទល្មើសប្រឆាំងនឹងសន្តិភាព និងឧក្រិដ្ឋកម្មសង្គ្រាម” (កថាខណ្ឌ ១១៨)។ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | |
| 24. | សេចក្តីព្រាងក្រមអំពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ UN Doc. A/2693 ឆ្នាំ1954 របស់គណៈកម្មាធិការច្បាប់អន្តរជាតិឆ្នាំ១៩៥៤ | 1954 | មិនមាន | មាត្រា១៖ "បទល្មើសប្រឆាំងនឹងសន្តិភាពនិងសន្តិសុខមនុស្សជាតិដូចមានចែងនៅក្នុងក្រមនេះ គឺជាបទល្មើសក្រោមច្បាប់អន្តរជាតិដែលបុគ្គលទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើសនេះ ត្រូវតែផ្តន្ទាទោស"។<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>សេចក្តីព្រាងក្រមស្តីពីបទល្មើសរបស់ILC ឆ្នាំ១៩៥៤ មិនដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនោះទេ។ ទោះបីជាឯកសារនេះ ត្រូវបានពិចារណាថាជាភស្តុតាងនៃទស្សនៈរបស់អ្នកជំនាញនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់រដ្ឋដែលមានផលប្រយោជន៍ក្តី ក៏ការពិភាក្សាក្នុងចំណោមគណៈប្រតិភូរបស់រដ្ឋបង្ហាញថានៅក្នុងឆ្នាំ១៩៥៤ ឋានៈនៃចំណងទាក់ទងជម្លោះប្រដាប់អាវុធ មិនទាន់បង្កើតឡើងនៅឡើយទេ។ (បណ្តឹងឧទ្ធរណ៍របស់អៀង សារី កថាខណ្ឌ៤១) |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| 25. | **ឆ្នាំ ១៩៥៥-១៩៦៧** | | | |
| | គ្មានការវិវឌ្ឍន៍គួរឲ្យកត់សម្គាល់ទាក់ទងនឹងចំណងទាក់ទងជម្លោះប្រដាប់អាវុធនៅក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងលិខិតុបករណ៍អន្តរជាតិ ឬច្បាប់ជាតិ បើតាមការយល់ដឹងរបស់របស់មេធាវីការពារក្តី។ | | | |
| | **ឆ្នាំ ១៩៦៨-១៩៨៤** | | | |
| | លក្ខន្តិកៈនៃអនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ១៩៦៨, U.N.G.A. Res. 2391 (XXIII) ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៦៨ | 1968 | មិនមាន | មាត្រា I(ខ)៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទោះជាប្រព្រឹត្តនៅក្នុងពេលសង្គ្រាម ឬនៅពេលសន្តិភាព ឲ្យតែបទល្មើសនោះមានចែងនៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ Nürnberg ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៤៥ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយសេចក្តីសម្រេចចិត្ត៣(I) ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៤៦ និងសេចក្តីសម្រេចចិត្ត ៩៥ (I) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦ របស់ |

| លេខ | ឈ្មោះប្រភពឯកសារ | កាល បរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | មហាសន្និបាតអង្គការសហប្រជាជាតិ...”<br><br>**សេចក្តីអត្ថាធិប្បាយៈ**<br>លក្ខន្តិកៈឆ្នាំ១៩៦៨នៃអនុសញ្ញាស្តីពីអាជ្ញាយុកាល មិនមានការគាំទ្រពីរដ្ឋគួរឲ្យកត់សម្គាល់នោះទេ។ វាជា “ឯកសារមានលក្ខណៈនយោបាយសំខាន់មួយ” ដែលបានទទួលសម្លេងគាំទ្រតិចជាងពាក់កណ្តាលសមាជិក១២៦រដ្ឋរបស់អង្គការសហប្រជាជាតិ នៅពេលដែលអនុម័ត។ (បណ្តឹងឧទ្ធរណ៍លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចលើចំណាងទាក់ទងជម្លោះប្រដាប់អាវុធ កថាខណ្ឌ៤៧)។ |
| 26. | អនុសញ្ញាអន្តរជាតិឆ្នាំ១៩៧៣ ស្តីពីការគាបសង្កត់ និងការដាក់ទណ្ឌកម្មលើបទល្មើសបំបែកពូជសាសន៍, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៣ | 1973 | មិនមាន | មាត្រា១៖ “រដ្ឋភាគីនៃអនុសញ្ញាបច្ចុប្បន្ន ប្រកាសថា *បទល្មើសបំបែកពូជសាសន៍* គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើអមនុស្សធម៌នោះ កើតចេញមកពីគោលនយោបាយ និងការអនុវត្ត *ការបំបែកពូជសាសន៍* និងគោលការណ៍ និងការអនុវត្តស្រដៀងគ្នានៃការបំបែកពូជសាសន៍ និងការរើសអើង ដូចមានចែងនៅក្នុងមាត្រាII នៃអនុសញ្ញា គឺជាបទល្មើសដែលរំលោភលើគោលការណ៍ |



Original EN: 00755484-00755505

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ច្បាប់អន្តរជាតិ ជាពិសេសគោលបំណង និងគោលការណ៍នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិហើយបទល្មើសនោះ គឺជាការគំរាមកំហែងធ្ងន់ធ្ងរដល់សន្តិភាព និងសន្តិសុខអន្តរជាតិ”។<br><br>**សេចក្តីអត្ថាធិប្បាយៈ**<br>នៅពេលអនុសញ្ញាស្តីពីការបំបែកពូជសាសន៍ បានចូលជាធរមាននៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៦ មិនមានប្រទេសលោកខាងលិចណាមួយបានចុះហត្ថលេខាលើអនុសញ្ញានោះទេ ដែលបង្ហាញអំពីភាពមិនគ្រប់គ្រាន់នៃការអនុវត្ត និង*មតិយោបល់ច្បាប់*របស់រដ្ឋទាំងអស់។ (បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចលើទំនាក់ទំនងជម្លោះប្រដាប់អាវុធ កថាខណ្ឌ៥០)។ |
| 27. | អនុសញ្ញាអឺរ៉ុបស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៧៤។ | 1974 | មិនមាន | មាត្រា១៖ “រដ្ឋភាគីនីមួយៗ ទទួលអនុម័តវិធានការចាំបាច់ដើម្បីធានាថាអាជ្ញាយុកាលមិនត្រូវអនុវត្តលើការកាត់សេចក្តីចំពោះបទល្មើសដូចខាងក្រោម ឬការអនុវត្តការប្រកាសទោស ដែលកំណត់ចំពោះបទល្មើសទាំងនោះទេ ត្រង់ចំណុចដែលបទល្មើសទាំងនោះត្រូវបានដាក់ទណ្ឌកម្មក្រោមច្បាប់ជាតិរបស់រដ្ឋនោះ៖ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ១. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីការហាមឃាត់និងការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលអនុម័តកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ដោយមហាសន្និបាតអង្គការសហប្រជាជាតិ។” |
| 28. | **ឆ្នាំ ១៩៨៥-១៩៩៨** | | | |
| | របាយការណ៍របស់អគ្គលេខាធិការអនុលោមតាមកថាខណ្ឌ២នៃសេចក្តីសម្រេចចិត្តក្រុមប្រឹក្សាសន្តិសុខលេខ ៨០៨ UN Doc. S/25704, ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៩៣ | 1993 | មាន | “ផ្នែកនៃច្បាប់មនុស្សធម៌អន្តរជាតិតាមប្រពៃណីនិយម ដែលគ្មានវិមតិសង្ស័យ បានក្លាយជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺជាច្បាប់ដែលយកមកអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធដូចមានចែងនៅក្នុង៖ អនុសញ្ញាហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដើម្បីការពារជនរងគ្រោះដោយសារសង្គ្រាម, ... អនុសញ្ញាទីក្រុង Hague (IV) ដែលទាក់ទងនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើដីគោក និងបទបញ្ជាដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងអនុសញ្ញានោះចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩០៧, ... អនុសញ្ញាស្តីពីការហាមឃាត់និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨, ... និង [ធម្មនុញ្ញរបស់តុលាការIMT]ចុះថ្ងៃទី០៨ |



Original EN: 00755484-00755505

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ខែសីហា ឆ្នាំ១៩៤៥”។ (កថាខណ្ឌ ៣៥)<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>ក្រោយឆ្នាំ១៩៧៩ ការវិវឌ្ឍន៍នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនសំខាន់ទេ ចំពោះឋានៈនៃទំនាក់ទំនងជម្លោះប្រដាប់អាវុធចាប់ពីឆ្នាំ១៩៧៥-១៩៧៩។ (បណ្តឹងឧទ្ធរណ៍ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចលើទំនាក់ទំនងជម្លោះប្រដាប់អាវុធ កថាខណ្ឌ៥១)។ |
| 29. | លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, UN Res. 827 អនុម័តនៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣ | 1993 | មាន | មាត្រា៥៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ<br>“តុលាការអន្តរជាតិត្រូវមានអំណាចកាត់សេចក្តីលើបុគ្គលទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដូចខាងក្រោមនេះ នៅពេលប្រព្រឹត្តក្នុងពេលជម្លោះប្រដាប់អាវុធ ទោះជាក្នុងចរិតលក្ខណៈជាអន្តរជាតិ ឬជាតិក្តី និងសំដៅប្រឆាំងនឹងប្រជាជនស៊ីវិល...”<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>លក្ខន្តិកៈតុលាការICTY ដាក់បញ្ចូលនូវទំនាក់ទង ហើយប្រវត្តិនៃសេចក្តីព្រាង បង្ហាញថា អ្នកធ្វើសេចក្តីព្រាង បានពិចារណា |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ទោះបីជាយុត្តិសាស្ត្ររបស់តុលាការICTY បានសម្រេចថា លក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនង គឺជាលក្ខខណ្ឌយុត្តាធិការសម្រាប់តុលាការICTY ក៏ចៅក្រមរបស់តុលាការICTY បានប្រើប្រាស់វិធីសាស្ត្រទូលាយដើម្បីបកស្រាយផងដែរ។ (បណ្តឹងឧទ្ធរណ៍របស់អៀងសារីប្រឆាំងនឹងសេចក្តីសម្រេចលើទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ កថាខណ្ឌ៥២-៥៣)។ |
| 30. | លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា, UN Doc. S/RES/955, ឆ្នាំ១៩៩៤ | 1994 | មិនមាន | មាត្រា ៣៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ<br>“តុលាការអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ត្រូវមានអំណាចកាត់សេចក្តីលើបុគ្គលទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដូចតទៅ នៅពេលប្រព្រឹត្តជាផ្នែកនៃការវាយប្រហារជាទូទៅឬជាប្រព័ន្ធទៅលើប្រជាជនស៊ីវិលដោយសារតែមូលហេតុជាតិសាសន៍ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា... ” |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | **សេចក្តីអត្ថាធិប្បាយ៖**<br>សាស្ត្រាចារ្យ Schabas បានតវ៉ាថា អគ្គលេខាធិការអង្គការសហ-ប្រជាជាតិ យល់ឃើញថាលក្ខន្តិកៈតុលាការICTR "ជាការមិនអនុវត្តតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ" (*សូមមើល* បណ្តឹងឧទ្ធរណ៍ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចលើទំនាក់ទំនងជម្លោះប្រដាប់អាវុធ កថាខណ្ឌ៥៤)។ |
| 31. | របាយការណ៍របស់អគ្គលេខាធិការ អនុលោមតាមកថាខណ្ឌ៥ នៃសេចក្តីសម្រេចចិត្តក្រុមប្រឹក្សាសន្តិសុខ ៩៥៥, UN Doc. S/1995/134, ឆ្នាំ១៩៩៥ | 1995 | មិនច្បាស់ | "... ក្រុមប្រឹក្សាសន្តិសុខ បានជ្រើសរើសប្រើប្រាស់វិធីសាស្ត្រកាន់តែទូលាយ សម្រាប់ជម្រើសនៃច្បាប់ជាធរមាន ជាជាងការប្រើប្រាស់វិធីសាស្ត្រដែលកំណត់នៅក្នុងលក្ខន្តិកៈរបស់តុលាការយូហ្គោស្លាវី និងបានរួមបញ្ចូលនៅក្នុងយុត្តាធិការលើរឿងក្តីនៃលិខិតុបករណ៍អន្តរជាតិរបស់តុលាការរវ៉ាន់ដា ដោយមិនគិតថាតើលិខិតូបករណ៍ទាំងនេះ ត្រូវបានពិចារណាជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬថាតើលិខិតូបករណ៍ទាំងនេះ ជាប់ទាក់ទងជាទម្លាប់ ជាមួយនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនៃចារីដែលប្រព្រឹត្តបទល្មើស។ អាស្រ័យហេតុនេះ មាត្រា៤នៃ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | លក្ខន្តិកៈ រួមបញ្ចូលការរំលោភបំពានលើពិធីសារបន្ថែមII ដែលមិនត្រូវបានទទួលស្គាល់ជាសកល ថាជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងនៅពេលកំណត់ជាបទល្មើសចំពោះមាត្រារួម៣ នៃអនុសញ្ញាហ្សឺណែវទាំងបួន"។ (កថាខណ្ឌ ១២) |
| 32. | របាយការណ៍នៃគណៈកម្មាធិការត្រៀមស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ វ៉ុល ១ (ដំណើរការនីតិវិធីរបស់គណៈកម្មាធិការត្រៀម ក្នុងអំឡុងខែ មីនា-មេសា និងខែសីហា ឆ្នាំ១៩៩៦), Doc. A/51/22 | 1996 | មិនច្បាស់ | "ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ" "<u>Nexus to armed conflict</u> មានទស្សនៈខុសគ្នាថាតើចាំបាច់ឬមិនចាំបាច់ដើម្បីបញ្ចូលទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ដែលមិនបានបញ្ចូលនៅក្នុងលក្ខន្តិកៈតុលាការរវ៉ាន់ដា។ គណៈប្រតិភូមួយចំនួនបានបង្ហាញទស្សនៈថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានប្រព្រឹត្តជាប់ជានិច្ចក្នុងស្ថានការដែលពាក់ព័ន្ធនឹងប្រភេទមួយចំនួននៃជម្លោះប្រដាប់អាវុធ ដូចដែលបានបង្ហាញដោយតុលាការមិនអចិន្ត្រៃយ៍។ ច្បាប់ជាធរមាននោះ តម្រូវឱ្យមានប្រភេទទំនាក់ទំនងមួយចំនួនជាមួយនឹងជម្លោះប្រដាប់អាវុធក្នុងន័យទូលាយ ដោយសំអាងលើធម្មនុញ្ញNürnberg , លក្ខន្តិកៈតុលាការយូហ្គោស្លាវី, អនុស្សរណៈរបស់ប្រធាននិង និងរឿងក្តី <u>Nikolić</u> ដែលកំពុងដំណើរ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ការនៅចំពោះមុខតុលាការ។ ហើយច្បាប់ទំនៀមទម្លាប់នោះ មិនបានផ្លាស់ប្តូរទេ ដោយសារតែការអនុម័តយកលិខិតុបករណ៍សិទ្ធិមនុស្ស ដែលចែងអំពីនីតិវិធីមួយចំនួន ដើម្បីដោះស្រាយការរំលោភបំពាន ឬលក្ខន្តិកៈតុលាការរវ៉ាន់ដា"។ (កថាខណ្ឌ ៨៨)<br><br>"ទោះបីជាយ៉ាងណាក៏ដោយ គណៈប្រតិភូមួយចំនួនបានបង្ហាញទស្សនៈថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចកើតមានក្នុងពេលជម្លោះប្រដាប់អាវុធ ឬក្នុងពេលសន្តិភាព និងទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធដែលមានចែងនៅក្នុងធម្មនុញ្ញតុលាការ Nürnberg មិនមែនជាលក្ខខណ្ឌតម្រូវផ្អែកតាមច្បាប់ជាធរមាន ដោយផ្តោតការយកចិត្តទុកដាក់លើមាត្រាI នៃអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង, អនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះច្បាប់សង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, លក្ខន្តិកៈតុលាការរវ៉ាន់ដា, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការយូហ្គោស្លាវី នៅក្នុងរឿងក្តី Tadić និងសេចក្តីព្រាងក្រម។ ទស្សនៈនេះក៏បានបង្ហាញថា |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ទោះបីជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជារឿយៗបានកើតឡើងនៅក្នុងស្ថានភាពដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ក៏ឧក្រិដ្ឋកម្មទាំងនេះអាចកើតមានឡើងនៅក្នុងពេលសន្តិភាព ឬនៅក្នុងស្ថានភាពដែលមិនច្បាស់លាស់ផងដែរ”។ (កថាខណ្ឌ៨៩)<br><br>“ទស្សនៈត្រូវបានបង្ហាញថា បទល្មើសដែលកើតឡើងក្នុងពេលសន្តិភាព អាចតម្រូវឱ្យមានកម្រិត ឬលក្ខណៈវិនិច្ឆ័យអន្តរជាតិបន្ថែម ដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មដែលសមស្របសម្រាប់ការសម្រេចរបស់តុលាការ និងប្រហែលជាកំណត់ត្រឹមបុគ្គលដែលអាចប្រព្រឹត្តបទល្មើសបែបនោះប៉ុណ្ណោះ។ គណៈប្រតិភូមួយចំនួនចោទសួរអំពីតម្រូវការសម្រាប់លក្ខណៈវិនិច្ឆ័យបន្ថែម នៅពេលសន្មតថា អំពើអមនុស្សធម៌ ឬអំពើដែលមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ត្រូវបានប្រព្រឹត្តជាលក្ខណៈទូទៅ និងជាប្រព័ន្ធ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើសំណើសុំឱ្យបកស្រាយលក្ខណៈវិនិច្ឆ័យទូទៅនេះ ដើម្បីបង្ហាញឱ្យកាន់តែច្បាស់អំពីប្រភេទបទល្មើសដែលសមស្របសម្រាប់សេចក្តីសម្រេចអន្តរជាតិ”។ (កថាខណ្ឌ |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ៩០)<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>"កិច្ចពិភាក្សាបានបន្តលើប្រធានបទ[ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ] ក្នុងពេលប្រជុំរបស់គណៈកម្មាធិការត្រៀម"។<br>(WILLIAM A. SCHABAS, តុលាការព្រហ្មទណ្ឌអន្តរជាតិ៖ សេចក្តីអត្ថាធិប្បាយស្តីពីលក្ខន្តិកៈទីក្រុងរ៉ូម ១៤៦ (២០១០))។ |
| 33. | គណៈកម្មាធិការត្រៀម សម្រាប់ធ្វើសេចក្តីព្រាងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ និងរបាយការណ៍របស់គណៈកម្មាធិការត្រៀមស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ, A/CONF.183/ 2/Add.1, ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៩៨ | 1998 | មិនច្បាស់ | <u>ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ</u><br>១. "សម្រាប់គោលបំណងលក្ខន្តិកៈបច្ចុប្បន្ន ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាអំពើណាមួយដូចខាងក្រោម នៅពេលប្រព្រឹត្ត៖<br><br>[ជាផ្នែកនៃការវាយប្រហារជាទូទៅ [និង] [ឬ] ជាប្រព័ន្ធប្រឆាំងនឹងប្រជាជន] [ស៊ីវិល]ណាមួយ [ដែលបានប្រព្រឹត្តលើទ្រង់ទ្រាយធំ] [នៅក្នុងជម្លោះប្រដាប់អាវុធ] [ដោយសារតែមូលហេតុនយោបាយ ទស្សនៈវិជ្ជា ពូជសាសន៍ ជាតិពន្ធុ ឬសាសនា ឬមូលហេតុដែលកំណត់ដោយខុសច្បាប់ផ្សេងទៀត] ]" (ទំព័រ ២៥- |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | ២៦)<br><br>**សេចក្តីអត្ថាធិប្បាយៈ**<br>"... ទស្សនៈ [សម្រាប់និយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលរួមបញ្ចូលទាំងជម្រើសទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ] មាននៅក្នុងអត្ថបទរួមជាស្ពាន ដែលជាមូលដ្ឋានសម្រាប់ប្រជុំពិភាក្សាសម្រេចនៅខែកក្កដា ឆ្នាំ១៩៩៨ នៅទីក្រុងរ៉ូម។ ផ្ទុយគ្នានឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និយមន័យជារួមនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានធ្វើឲ្យអ្នកធ្វើសេចក្តីព្រាងចាប់ន័យមិនបានរហូតដល់ថ្ងៃចុងក្រោយនៃសន្និសិទការទូត។ ប្រទេសចិន ឥណ្ឌា សហព័ន្ធរុស្ស៊ី និងរដ្ឋជាច្រើនទៀត បានបន្តគាំទ្រការរក្សាទុកលក្ខខណ្ឌនៃទំនាក់ទំនងក្នុងពេលសង្គ្រាម ..." (Beth Van Schaack, *The Definition of Crimes Against Humanity: Resolving the Incoherence*, 37 COLUM. J. OF TRANSNAT'L L. 787, 844 (1999)). |
| 34. | "សន្និសិទការទូតអង្គការសហប្រជាជាតិរបស់បុណ្ណទូត ស្តីពីការបង្កើតតុលាការ | 1998 | មិនច្បាស់ | "**ប្រធាន** ក្នុងពេលសង្ខេបកិច្ចពិភាក្សា បានលើកឡើង ... មតិយោបល់បានបង្ហាញខុសៗគ្នា អំពីថាតើគួរតែមាន ឬមិនគួរមាន |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | ព្រហ្មទណ្ឌអន្តរជាតិ” កិច្ចប្រជុំលើកទី៣ នៃគណៈកម្មាធិការទាំងមូល, UN Doc. A/CONF.183/C.1/SR.3, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៨ | | | ទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ ហើយគណៈប្រតិភូមួយចំនួន ក៏បានស្នើសុំឱ្យកំណត់ “ជម្លោះប្រដាប់អាវុធ” ដែលមានក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ” (កថាខណ្ឌ ១៧៤, ១៧៦)។ |
| 35. | លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលផ្សាយជា A/CONF.183/9, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ | 1998 | មិនមាន | មាត្រា ៧(១)៖ “សម្រាប់គោលបំណងនៃលក្ខន្តិៈនេះ “ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ” គឺជាអំពើណាមួយដូចតទៅ នៅពេលដែលការប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ ដែលសំដៅប្រឆាំងលើប្រជាជនស៊ីវិលណាមួយ ដោយបានដឹងឮនៃការវាយប្រហារ...”<br><br>**សេចក្តីអត្ថាធិប្បាយ៖**<br>អង្គជំនុំជម្រះសាលាដំបូង ដកស្រង់ការចចារលើលក្ខន្តិកៈតុលាការ ICC ដែលបានបង្ហាញ “ហួសពីវិមតិសង្ស័យ”ថា ត្រឹមឆ្នាំ១៩៩៨ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លែងត្រូវការលក្ខខណ្ឌតម្រូវទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ។ ទោះបីជាយ៉ាងណាក៏កិច្ចពិភាក្សាដែលនាំឱ្យឈានដល់ការអនុម័តលក្ខន្តិកៈICC |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | បង្ហាញថា បញ្ហាទំនាក់ទំនងជម្លោះប្រដាប់អាវុធ មិនបានដោះស្រាយមុនពេលអនុម័តលក្ខន្តិកៈតុលាការICC នោះទេ។ (បណ្ដឹងឧទ្ធរណ៍ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចលើទំនាក់ទំនងជម្លោះប្រដាប់អាវុធ កថាខណ្ឌ៥៥)។ |
| 36. | **ឆ្នាំ ១៩៩៩-២០១១** | | | |
| | របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបង្កើតឡើងអនុលោមតាមសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតលេខ 52/135, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ | 1999 | មិនមាន | “ចំណងទាក់ទងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាមួយនឹងជម្លោះប្រដាប់អាវុធ ត្រូវបានកាត់ផ្ដាច់ត្រឹមឆ្នាំ១៩៧៥” (កថាខណ្ឌ៧១)។<br><br>**សេចក្ដីអត្ថាធិប្បាយ៖**<br>របាយការណ៍នេះមិនបានផ្ដល់ភស្តុតាងពិតប្រាកដនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់ពីឆ្នាំ១៩៧៥-១៩៧៩។ របាយការណ៍នេះដកស្រង់ចេញតែពីប្រភពពីរប៉ុណ្ណោះ ដែលប្រភពមួយក្នុងចំណោមនោះ ត្រូវបានសរសេរដោយសមាជិកមួយរូបនៃសមាជិករបស់ក្រុមអ្នកជំនាញ។ (បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសេចក្ដី |

| លេខ | ឈ្មោះប្រភពឯកសារ | កាលបរិច្ឆេទ | លក្ខខណ្ឌតម្រូវនៃទំនាក់ទំនង | អត្ថបទគាំទ្រ |
|---|---|---|---|---|
| | | | | សម្រេចលើទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ កថាខណ្ឌ៣៦ ជើងទំព័រ៧៦)។ |
| 37. | លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន, U.N.S.C. Res. 1315 ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០០ | 2000 | មិនមាន | មាត្រា ៖ "តុលាការពិសេស ត្រូវមានអំណាចក្នុងការកាត់ទោសបុគ្គលទាំងឡាយដែលបានប្រព្រឹត្តនូវបទឧក្រិដ្ឋដូចខាងក្រោម ដែលជាផ្នែកមួយនៃការវាយប្រហាររាលដាល ឬជាប្រព័ន្ធប្រឆាំងនឹងជនស៊ីវិល..."។ |
| 38. | ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បូកជាមួយច្បាប់វិសោធនកម្ម ដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ | 2004 | មិនមាន | "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុជាតិនយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ណាមួយ ដូចជា ..." |